# مدرسة اهل البيت

# សាលា អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោ្ហះហ្វ៍ ថ្នាក់ទី ១

(អាយុ ៥-៦ ឆ្នាំ)

រ៉ស៊ូលុលឡោះហ្វ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជា ជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា

មេរៀនទី ១- អល់ឡោះហ្វ៎ (الله)........................................៥
មេរៀនទី ២ - بِسْــمِ اللهِ الرَّحْمٰنِ الرَّحِيْمِ........................................៩
មេរៀនទី ៣ - កាលីម៉ាស្ហ (كلمة) លំដាប់ដំបូងបង្អស់...... ១៣
មេរៀនទី ៤ - កាលីម៉ាស្ហ (كلمة) - លំដាប់ទី ២ ................ ១៦
មេរៀនទី ៥ - កាលីម៉ាស្ហ (كلمة) - លំដាប់ទី ៣................ ១៩
មេរៀនទី ៦ - កាលីម៉ាស្ហ (كلمة) - លំដាប់ទី ៤ ................២២
មេរៀនទី ៧ - កាលីម៉ាស្ហ (كلمة) - លំដាប់ទី ៥................២៥
មេរៀនទី ៨ - កាលីម៉ាស្ហ (كلمة) ........................................២៨
មេរៀនទី ៩ - ស្វ៍ឡាវ៉ាត ............................................... ៣០
មេរៀនទី ១០ - អល់ឡ៍ហ្វ៎ អាក់បារ (الله أَكْبَر).................. ៣៤
មេរៀនទី ១១ - ស្វ៍ឡាត្ហ (صلاة) ........................................៣៧
មេរៀនទី ១២ - ស្វ៍ឡាត្ហ - គ្ហីយ៉ាម.................................. ៤០
មេរៀនទី ១៣ - ស្វ៍ឡាត្ហ - តាក់បីរ៉ទុល អិះហ្រ៎រ៉ម .......... ៤៣
មេរៀនទី ១៤ - ស្វ៍ឡាត្ហ - រូគុអ្ហ៍ (رُكوع)........................... ៤៦
មេរៀនទី ១៥ - ស្វ៍ឡាត្ហ - សាច្ហ៍ដ្ហាស្ហ (سجدة).................. ៤៩
មេរៀនទី ១៦ - ស្វ៍ឡាត្ហ - យ្ហ៊ុលុស ...............................៥២
មេរៀនទី ១៧ - ស្វ៍ឡាត្ហ - គ្ហូនូត...................................៥៤
មេរៀនទី ១៨ - កាយវិការក្នុងស្វ៍ឡាត្ហ.......................... ៥៧









**មេរៀនទី ១**

# អល់ឡោះហ្វ៍ (ﷲ)

មានតែព្រះមួយគត់ ព្រះនាមរបស់ព្រះអង្គគឺ **អល់ឡោះហ្វ៍** (ﷲ) ។

អល់ឡោះហ្វ៍ជាអ្នកណា ?

- ព្រះអង្គបានបង្កើតយើងទាំងអស់គ្នា និងបានបង្កើតអ្វីៗសព្វគ្រប់ដែលមាននៅជុំវិញយើង ។ ព្រះអង្គជាព្រះដែលបង្កើតយើង ។

- ព្រះអង្គគឺព្រះដែលមើលមកយើង ។ ព្រះអង្គជាព្រះអភិបាលយើង ។

- ព្រះអង្គគឺព្រះដែលយើងសូមជំនួយ ។ ព្រះអង្គជាព្រះជំនួយរបស់យើង ។

- ព្រះអង្គគឺព្រះដែលយើងស្តាប់បង្គាប់ ។ ព្រះអង្គជាព្រះម្ចាស់យើង ។

- ព្រះអង្គគឺព្រះដែលយើងនឹងវិលទៅរកវិញ ។ ព្រះអង្គគឺអល់ឡោះហ្វ៍ ។



**កិច្ចការសិស្ស ១**

ចូរទន្ទេញមេសូត្រឲ្យចាំរត់មាត់ ហើយផាត់ព័ណ៌នៅលើគំនូរ ។

អល់ឡោះហ្វ៍ជាព្រះដែលបង្កើតអ្វីៗសព្វគ្រប់ !











## កិច្ចការសិស្ស ២

# بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

(ខ្ញុំចាប់ផ្ដើម) ដោយព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។



ចូរគូររូបវត្ថុនានាចំនួនបី គម្បីចាប់ផ្ដើមដោយសូត្រ بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ ។



## មេរៀនទី ២

# بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

(ខ្ញុំចាប់ផ្ដើម) ដោយព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

យើងទាំងអស់គ្នាគប្បីថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ មុននឹងធ្វើមួយ ព្រោះយើងចង់ឲ្យអល់ឡោះហ្វ៍ជួយជ្រោមជ្រែងយើង ក្នុងគ្រប់ទង្វើ ។

បើយើងថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ អល់ឡោះហ្វ៍នឹងដេញស្ទៃត្ននឆ្ងាយពីយើង វាមិនអាចមកបំផ្លិចបំផ្លាញកិច្ចការរបស់យើងបានទេ ។

ក្នុងសម័យថ្ងៃមួយ ស្ត្រីជាភរិយាម្នាក់តែងតែថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ មុនចាប់ផ្ដើមធ្វើអ្វីមួយ ។

រៀងរាល់យប់ មុនចូលដំណេក គាត់ដោះចិញ្ចៀនគាត់ទុក

ក្នុងប្រអប់វា ។ យប់មួយ ដូចសព្វមួយដងដែរ មុននឹងដោះចិញ្ចៀនគាត់ គាត់ថា៖ بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ ។

ស្វាមីគាត់មិនជឿទេថា អល់ឡោះហ្វ៍មិនអាចជួយជ្រោមជ្រែងយើងបានទេ គ្រាន់តែថា بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ នោះ ។ យប់នោះ ដើម្បីបង្ហាញភរិយាគាត់ឲ្យដឹងថាពុំមានអ្វីប្លែកទេពេលសូត្រ بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ នោះ គាត់បានយកចិញ្ចៀនភរិយាគាត់ចេញពីប្រអប់វាទៅចោលក្នុងស្ទឹង ។

ព្រឹកឡើងស្ត្រីជាភរិយាប្រញាប់ទៅផ្សារពេក ក៏ពុំបានយកចិញ្ចៀនចេញពីប្រអប់វាមកពាក់វិញទេ ។

គាត់បានទិញត្រីមួយនៅឯផ្សារសម្រាប់ធ្វើម្ហូបពេលល្ងាច ។ មកដល់ផ្ទះវិញ គាត់បានកាត់ត្រី ដើម្បីយកទៅធ្វើម្ហូប ។ តើអ្នកគិតថាគាត់ឃើញមានអ្វីនៅក្នុងពោះត្រីនោះ ? មែន នៅក្នុងពោះត្រីនោះមានចិញ្ចៀនមួយវង់ ចិញ្ចៀនដែលស្វាមីគាត់បានចោលទៅក្នុងស្ទឹង ។ ត្រីបានលេបចិញ្ចៀនមួយវង់នេះទៅក្នុងពោះវា ។

ស្ត្រីជាភរិយាភ្ញាក់ផ្អើលអនេក ដែលបានឃើញចិញ្ចៀនគាត់



នៅក្នុងពោះត្រី ។ លុះស្វាមីគាត់ត្រឡប់មកផ្ទះវិញគាត់ក៏បានថ្លែងព្រឹត្តិការណ៍នេះប្រាប់ប្ដី ។

បុរសជាស្វាមីរន្ធត់ចិត្តអនេក ។ បន្ទាប់មកគាត់បានសារភាពប្រាប់ភរិយាគាត់ ថាគាត់បានចោលចិញ្ចៀនភរិយាគាត់ទៅក្នុងស្ទឹង ។ គាត់បានសារភាពដែរថាគាត់ស្ដាយក្រោយហើយពេលនេះទើបគាត់ជឿជាក់ថា អល់ឡោះហ្វ៍ការពារអ្នកណាដែលថា بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ ។

## ឧត្តមគតិរឿងនេះគឺ៖

ចូរសូត្រ بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ ជានិច្ចមុននឹងធ្វើអ្វីមួយ ដើម្បីអល់ឡោះហ្វ៍នឹងជួយការពារយើង ។ ពេលណាអល់ឡោះហ្វ៍ការពារយើង ពេលនោះពុំមានអ្នកណាអាចធ្វើបាបយើងបានឡើយ ។

**មេរៀនទី ៤**

# កាលីម៉ាស្ម៉ (كلمة) - លំដាប់ទី ២

## مُحَمَّدٌ رَّسُوْلُ اللّٰهِ

**មូហាំម៉ាដ់ﷺជាព្រះសាស្តារបស់អល់ឡោះហ្វ៍**

ព្រះសាស្តាមូហាំម៉ាដ់ﷺ បានបង្ហាត់បង្រៀនយើងនូវអ្វីដែលអល់ឡោះហ្វ៍តាអាឡាអនុញ្ញាតឲ្យយើងធ្វើ និងអ្វីដែលព្រះអង្គហាមមិនឲ្យយើងធ្វើ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺបានបង្ហាត់បង្រៀនយើង ឲ្យចេះនមស្ការអល់ឡោះហ្វ៍តាអាឡា និងចេះធ្វើអំពើល្អដើម្បីបំពេញព្រះហឫទ័យអល់ឡោះហ្វ៍តាអាឡា ។ បើយើងប្រតិបត្តិតាមអ្វីៗទាំងអស់ ដែលព្រះសាស្តាមូហាំម៉ាដ់ﷺ បានបង្ហាត់បង្រៀនយើង យើងនឹងទៅជាមុស្លីមល្អ ។

ព្រះសាស្តានានាជាគ្រូ ដែលអល់ឡោះហ្វ៍តាអាឡាបាន



**មេរៀនទី ៣**

# កាលីម៉ាស្ម៉ (كلمة) - លំដាប់ដំបូងបង្អស់

## لَا اِلٰهَ اِلَّا اللّٰهُ

**ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ**

មានតែព្រះមួយគត់ ព្រះនាមរបស់ព្រះអង្គគឺអល់ឡោះហ្វ៍ ។

អល់ឡោះហ្វ៍គឺព្រះដែលយើងគោរពបូជា ។

អល់ឡោះហ្វ៍គឺព្រះដែលយើងបួងសួង ។

អល់ឡោះហ្វ៍បានបង្កើតយើងទាំងអស់គ្នា ។
ដូច្នេះព្រះអង្គទ្រង់ញាណនូវអ្វី
ដែលល្អប្រសើរសម្រាប់យើង
ដូច្នេះហើយបានជាយើងត្រូវតែស្តាប់បង្គាប់ព្រះ

អង្គនិងធ្វើតាមព្រះអង្គ ។

អល់ឡោះហ្វ៍ការពារយើង ព្រះអង្គស្រឡាញ់យើងណាស់ ។

ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។



## កិច្ចការសិស្ស ៣

ចូរផាត់ព័ណ៌លើលេខខាងក្រោមនេះ  ដោយសូត្រសាឡើងវិញរឿយៗថា៖

لَا إِلٰهَ إِلَّا اللّٰهُ

**ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ**



អល់ឡោះហ្ទ៍តាអា្ទឡា បានមានព្រះបន្ទូលមកកាន់ព្រះសាស្ដាយើង គឺព្រះសាស្ដាមូហាំម៉ាដ្ស صلى الله عليه وآله وسلم ថាឲ្យព្រះអង្គបង្ហាត់បង្រៀនបណ្ដាមនុស្សនូវអ្វីៗសព្វគ្រប់ ដែលអល់ឡោះហ្ទ៍តាអា្ទឡាមានព្រះបំណងឲ្យមនុស្សដឹង ហើយបន្ទាប់ពីនោះ បណ្ដាអ៊ីមុាំមានតួនាទីជាអ្នកជួយជ្រោមជ្រែងបណ្ដាមនុស្ស និងមានតួនាទីជាអ្នករំលឹកព្រះរាជសារដល់បណ្ដាមនុស្ស ។



បញ្ជូនមក ដើម្បីបង្ហាញយើងនូវរបៀបបែបជាមុស្លីមល្អ ។

ព្រះសាស្ដានានាដឹងអ្វីៗទាំងអស់ ហើយមិនធ្វើអំពើណាមួយដែលអល់ឡោះហ្ទ៍តាអា្ទឡា មិនគាប់ព្រះហឫទ័យឡើយ ។

មានព្រះសាស្ដាច្រើនមកហើយ (១២៤ ០០០ អង្គ) ។

ព្រះសាស្ដាដំបូងបង្អស់គឺ អាដាំ عليه السلام ។

ព្រះសាស្ដាចុងក្រោយបង្អស់គឺ មូហាំម៉ាដ្ស صلى الله عليه وآله وسلم ។

## កិច្ចការសិស្ស ៤

مُحَمَّدٌ رَّسُوْلُ اللهِ

**មូហាំម៉ាដ់ﷺជាព្រះសាស្ដារបស់អល់ឡោះហ៍**



ព្រះសាស្ដាដំបូងបង្អស់គឺ អាដាំ ។

ព្រះសាស្ដាចុងក្រោយបង្អស់គឺ មូហាំម៉ាដ់ﷺ ។





## មេរៀនទី ៥

# កាលីម៉ាស់ (كلمة) - លំដាប់ទី ៣

عَلِيٌّ وَّلِيُّ اللهِ

**អ៊ីម៉ាំអាលី﵇ ជាទីស្រឡាញ់របស់អល់ឡោះហ៍**

អល់ឡោះហ៍តាអាឡាទ្រង់សព្វព្រះហឫទ័យ អ៊ីម៉ាំអាលី﵇ណាស់ ពីព្រោះព្រះអង្គ﵇ស្ដាប់បង្គាប់អល់ឡោះហ៍តាអាឡាជានិច្ច ហើយមិនដែលធ្វើឲ្យអល់ឡោះហ៍តាអាឡាទ្រង់ព្រះពិរោធឡើយ ។

អល់ឡោះហ៍តាអាឡាបានជ្រើសរើសអ៊ីម៉ាំអាលី﵇ ជាគ្រូបន្ទាប់ពីព្រះសាស្ដាមូហាំម៉ាដ់ﷺ ។

អ៊ីម៉ាំអាលី﵇មិនមែនជាសាស្ដាទេ តែព្រះអង្គជាអ៊ីម៉ាំ ។ ព្រះសាស្ដាមូហាំម៉ាដ់ ﷺយើងជាសាស្ដាចុងក្រោយបង្អស់ ។

## កិច្ចការសិស្ស ៦

ចូរផាត់ព័ណ៌លើរូបផ្កាយខាងក្រោមនេះ ព្រមទាំងចងចាំក្នុងចិត្តថាមានអ៊ីម៉ាំ ១២ អង្គ ។

وَصِيُّ رَسُوْلِ اللهِ

**អ៊ីម៉ាំអាលី عليه السلام ជាអ្នកស្នងព្រះសាស្តារបស់អល់ឡោះហ្វ៍**






## កិច្ចការសិស្ស ៥

ព្រមនឹងពេលដែលអ្នកផាត់ព័ណ៌ លើរូបបេះដូងខាងក្រោមនេះ ចូរអ្នកថានិងចងចាំមួយឃ្លានេះគឺ៖

عَلِيٌّ وَلِيُّ اللهِ

**អ៊ីម៉ាំអាលី عليه السلام ជាទីស្រឡាញ់របស់អល់ឡោះហ្វ៍**



**មេរៀនទី ៦**

# កាលីម៉ាស្ញ (كلمة) - លំដាប់ទី ៤

# وَصِيُّ رَسُوْلِ اللهِ

### អ៊ីម៉ាំអាុលី﵇ជាអ្នកស្នងព្រះសាស្តាﷺរបស់អល់ឡោះហ្វ៍﷿

ក្រោយពីព្រះសាស្តាមូហាំម៉ាដ្ញﷺបានចូលទិវង្គត និង ត្រឡប់ទៅរកអល់ឡោះហ្វ៍តាអាុឡាវិញ អ៊ីម៉ាំអាុលី﵇ជាគ្រូរបស់បណ្តាមុស្លីម ។

អាុលី﵇ជាមេដឹកនាំរបស់មុស្លីម ហើយមុស្លីមទាំងអស់គ្នាត្រូវតែស្តាប់ឱវាទអាុលី﵇ ។

ព្រះសាស្តាﷺបានបង្ហាត់ បង្រៀនសាសនាអ៊ីស្លាមដល់បណ្តាមនុស្ស ឯអ៊ីម៉ាំអាុលី﵇មានតួនាទីជាអ្នករំលឹកបណ្តាមនុស្សអំពីការអប់រំរបស់ព្រះសាស្តាﷺ ពេលណាពួកមុស្លីមបានភ្លេច ឬមិនបានយល់សម្តីរបស់ព្រះសាស្តាﷺ ។



ព្រះសាស្តាមូហាំម៉ាដ្ញﷺ ជាព្រះសាស្តាចុងក្រោយបង្អស់ ហើយបន្ទាប់ពីព្រះអង្គមានអ៊ីម៉ាំអាុលី﵇ ។ អ៊ីម៉ាំដំបូងបង្អស់គឺអ៊ីម៉ាំអាុលី﵇ ។ អ៊ីម៉ាំចុងក្រោយបង្អស់គឺអ៊ីម៉ាំ មូហាំម៉ាដ្ញ ម៉ាស្ញខ្ញី﵇ ។ ព្រះអង្គមានព្រះជន្មនៅឡើយ ហើយព្រះអង្គជាអ៊ីម៉ាំរបស់សម័យកាលយើង ។

**មេរៀនទី ៨**

# កាលីម៉ាស្ទ៍

## لَا اِلٰهَ اِلَّا اللهُ

**ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ**

## مُحَمَّدٌ رَّسُوْلُ اللهِ

**មូហ្ហាំម៉ាដ្ឋﷺជាព្រះសាស្តារបស់អល់ឡោះហ្វ៍**

## عَلِيٌّ وَّلِيُّ اللهِ

**អ៊ីមុាំអុាលីعليه السلامជាទីស្រឡាញ់របស់អល់ឡោះហ្វ៍**

## وَصِيُّ رَسُوْلِ اللهِ

**អ៊ីមុាំអុាលីعليه السلامជាអ្នកស្នងព្រះសាស្តារបស់អល់ឡោះហ្វ៍**



**មេរៀនទី ៧**

# កាលីម៉ាស្ទ៍ (كلمة) - លំដាប់ទី ៥

## وَ خَلِيْفَتُهُ بِلَا فَصْلِ

**អ៊ីមុាំអុាលីعليه السلامជាខ៉ូលិហ្វទីមួយ**

ខ៉ូលិហ្វមានន័យថា មេដឹកនាំ អ្នកដែលមនុស្សស្តាប់ឱវាទ ។ អ៊ីមុាំអុាលីعليه السلامជាមេដឹកនាំទីមួយរបស់បណ្តាមុស្លីម បន្ទាប់ពីព្រះសាស្តាមូហ្ហាំម៉ាដ្ឋﷺ បានវិលត្រឡប់ទៅឯអល់ឡោះហ្វ៍តាអាឡាវិញ ។

មនុស្សអាក្រក់ដ៏ច្រើនបានអះអាងថាខ្លួនជាមេដឹកនាំ តែពួកគេជាមនុស្សខុស ព្រោះពួកគេមិនបានស្តាប់បង្គាប់អល់ឡោះហ្វ៍តាអាឡាទេ ។

អល់ឡោះហ្វ៍តាអាឡាបានជ្រើសរើសអ៊ីមុាំអុាលីعليه السلام ជាមេដឹកនាំរបស់បណ្តាមុស្លីម ឲ្យពួកគេស្តាប់ឱវាទអ៊ីមុាំអុាលីعليه السلام បន្ទាប់ពីព្រះសាស្តារបស់អល់ឡោះហ្វ៍តាអាឡា ។

មនុស្សល្អទាំងអស់បានតាមអ៊ីម៉ាំអាលី(عليه السلام) អ៊ីម៉ាំអាលី(عليه السلام) បានបង្ហាត់បង្រៀនជានិច្ចឲ្យពួកគេក្លាយទៅជាមុស្លីមល្អ និង គាប់ព្រះហឫទ័យអល់ឡោះហ្វ៍តាអាឡា ។
អ៊ីម៉ាំអាលី(عليه السلام)មានប្រាជ្ញាឈ្លាសវៃណាស់ ព្រះអង្គ(عليه السلام)បានបង្ហាត់បង្រៀនបណ្ដាមុស្លីមនូវអ្វីៗយ៉ាងច្រើន ។



**កិច្ចការសិស្ស ៧**

ព្រមនឹងផាត់ព័ណ៌លើរូបខាងក្រោមនេះ ចូរចងចាំ៖

وَ خَلِيْفَتُهُ بِلَا فَصْلِ

**អ៊ីម៉ាំអាលី(عليه السلام)ជាខ៊ុលិហ្វទីមួយ**




**ទី ១**

**កិច្ចការសិស្ស ៩**

# ស្វ៏ឡាវ៉ាត

## اَللّٰهُمَّ صَلِ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

**អល់ឡោះហ្ស៍អឺយ! សូមព្រះរាជទានសិរីសួស្តីមកលើព្រះសាស្តា មូហាំម៉ាដ់និងអាស្ល៍លុល-បៃត៍ (ក្រុមគ្រួសារ) ព្រះអង្គផង ។**

ចូរផាត់ព័ណ៌លើគ្រាប់ទាំង ១៤ ដែលមាននៅលើតាស់ប៊ិះហ៍ស្វឡាវ៉ាតពិសេសសម្រាប់ព្រះសាស្តា صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គ (ប៊ីប៊ី ហ្វាទិ៍ម៉ាស្ល់ سلام الله عليها និងអ៊ីម៉ាំទាំង ១២ អង្គ ១+១+១២=១៤) នៅខាងក្រោមនេះ ។ ចូរសូត្រស្វ៏ឡាវ៉ាតសាចុះឡើង ក្នុងពេលផាត់ព័ណ៌លើគ្រាប់តាស់ប៊ិះហ៍ ។



## وَ خَلِيْفَتُهُ بِلَا فَصْلِ

**អ៊ីម៉ាំអាលី عليه السلام ជាខ៊ិលិហ្វទីមួយ**

ចូរទន្ទេញកាលីម៉ាស្ល់ឲ្យចាំស្ទាត់ ។

**មេរៀនទី ៩**

# ស្វ៏ឡាវ៉ាត

اَللّٰهُمَّ صَلِ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

**អល់ឡោះហ៍អើយ! សូមព្រះរាជទានសិរីសួស្តីមកលើព្រះសាស្តា មូហ៊ាំម៉ាដ់ និងអាស្ហ៍លុល-បៃត៍ (ក្រុមគ្រួសារ) ព្រះអង្គផង ។**

គេហៅក្រុមគ្រួសាររបស់ព្រះសាស្តាថា "អាស្ហ៍លុល-បៃត៍" ។ ក្រុមគ្រួសារនេះមានរាជបុត្រីរបស់ព្រះអង្គគឺ ប៊ីប៊ីហ្វាទីម៉ាស្ហ៍ سلام الله عليها និងអ៊ីម៉ាំទាំង ១២ អង្គ عليهم السلام ។

រាល់ពេលដែលអ្នកទាំងអស់គ្នា បានឮព្រះនាមរបស់ព្រះសាស្តា ﷺ និងរាជបុត្រីរបស់ព្រះអង្គ سلام الله عليها ពេលនោះអ្នកទាំងអស់គ្នាគប្បីសូត្រស្វ៏ឡាវ៉ាត ។



ពេលណាអ្នកទាំងអស់គ្នាបានឮព្រះនាមរបស់អ៊ីម៉ាំទី ១២ របស់យើង គឺអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-ម៉ាស្ហ៍ឌី عليه السلام អ្នកទាំងអស់គ្នាគប្បីសូត្រស្វ៏ឡាវ៉ាត ថែមទាំងងើបឈរ យកដៃស្តាំដាក់លើក្បាលហើយឱនក្បាលដើម្បីគោរពព្រះអង្គ ។ ព្រោះអ៊ីម៉ាំទី១២ عليه السلام របស់យើងទ្រង់គង់ព្រះជន្មនៅឡើយ ។

ពេលណាអ្នកទាំងអស់គ្នានៅឯម៉ាស់យ៊ិដ្ហ ហើយអ្នកទាំងអស់គ្នាមិនយល់ន័យឃុតបាស្ហ៍ ពេលនោះអ្នកទាំងអស់គ្នាគប្បីសូត្រស្វ៏ឡាវ៉ាតឲ្យច្រើន ។

ពេលដែលអ្នកទាំងអស់គ្នាសូត្រស្វ៏ឡាវាត អ្នកទាំងអស់គ្នាសូមឲ្យអល់ឡោះហ៍ តាអាឡាទ្រង់ព្រះរាជទាននូវសិរីសួស្តីមកឲ្យព្រះសាស្តា ﷺ និងព្រះរាជកុលដ្ឋាន (គឺគ្រួសារ) របស់ព្រះអង្គ ﷺ ។ អ៊ីនស្ហា-អល់ឡោះហ៍ នៅថ្ងៃ គ៊ីយ៉ាម៉ាត់ ព្រះសាស្តា ﷺ និងព្រះរាជកុលដ្ឋានព្រះអង្គនឹងសូមឲ្យអល់ឡោះហ៍តាអាឡា លើកលែងទោសឲ្យអ្នកទាំងអស់គ្នាវិញសម្រាប់គ្រប់ស្វ៏ឡាវ៉ាត ដែលអ្នកទាំងអស់គ្នាបានសូត្រឲ្យព្រះអង្គទាំងអស់នោះ ។

## កិច្ចការសិស្ស ១០

ចូរផាត់ព័ណ៌ដោយសូត្រថា៖

# អល់ឡ៏ហ៊្វូ អាក់ប៉ារ

# (اَللّٰهُ اَكْبَرُ)




**ធំធ្វើងបំផុត (លើសអ្វីៗទាំងអស់)**





## មេរៀនទី ១០

# អល់ឡ៏ហ្វូ អាក់ប៉ារ (الله أَكْبَر)

អល់ឡ៏ហ្វូ អាក់ប៉ារ មានន័យថា អល់ឡោះហ្វ៍ធំធ្ងើងបំផុត (លើសអ្វីៗទាំងអស់) ។

អល់ឡោះហ្វ៍បានបង្កើតអ្វីៗសព្វគ្រប់ ។

ព្រះអង្គបានបង្កើតពិភពលោក ។
ព្រះអង្គបានបង្កើតយើងគ្រប់គ្នា អ្នកទាំងអស់គ្នា ខ្ញុំ ម្ដាយអ្នកទាំងអស់គ្នា ពុកនិងអ្នកឯទៀតទាំងអស់គ្នា ។
ព្រះអង្គបានបង្កើតសត្វ ។
ព្រះអង្គបានបង្កើតដើមឈើនិងផ្កា ។
ព្រះអង្គបានបង្កើតមេឃ ជាមួយថ្ងៃនិងខែ ។
ព្រះអង្គបានបង្កើតអ្វីៗទាំងអស់ ។
ព្រះអង្គធំធ្ងើងណាស់ ។

អល់ឡោះហ្វ៍ខ្លាំងពូកែផងដែរ ។



ព្រះអង្គខ្លាំងពូកែលើសមនុស្សទាំងអស់ ។
ព្រះអង្គខ្លាំងពូកែលើសសត្វទាំងអស់ ។
ព្រះអង្គខ្លាំងពូកែលើសអ្វីៗទាំងអស់ ។
ព្រះអង្គធំធ្ងើងណាស់ ។

អល់ឡោះហ្វ៍ឆ្លាតបំផុត
ព្រះអង្គឆ្លាតលើសមនុស្សទាំងអស់
ព្រះអង្គធំធ្ងើងណាស់ ។

អល់ឡោះហ្វ៍មិនត្រូវការអ្នកណាទេ ។
យើងទាំងអស់គ្នាត្រូវការអល់ឡោះហ្វ៍ ។
ព្រះអង្គធំធ្ងើងណាស់ ។

ពេលណាអ្នកទាំងអស់គ្នាបានឃើញអ្វីមួយ ដែលធំសម្បើម និងអស្ចារ្យ ពេលនោះចូរអ្នកទាំងអស់គ្នាថា អល់ឡ៏ហ្វូ អាក់បារ (الله أَكْبَر) ព្រោះអល់ឡោះហ្វ៍ធំធ្ងើងលើសអ្វីៗដែលអ្នកទាំងអស់គ្នាបានឃើញនោះទៅទៀត ។

**មេរៀនទី ១២**

# ស្វ៍ឡាត្ទ៉ - គ្វីយ៉ាម

មុនចាប់ផ្ដើមប្រតិបត្តិស្វ៍ឡាត្ទ៉ អ្នកទាំងអស់គ្នាត្រូវប្រតិបត្តិគ្វីយ៉ាម ។

គ្វីយ៉ាមគឺវិធីឈរពិសេសក្នុងពេលបំពេញស្វ៍ឡាត្ទ៉ ។

គ្វីយ៉ាមប្រុសនិងគ្វីយ៉ាមស្រីខុសគ្នា ។

រូបខាងក្រោមនេះបង្ហាញត្ទ៉លិបនិងត្ទ៉លីបាស្ទ៉ ប្អូនស្រីរបស់ត្ទ៉លិបកំពុងឈរគ្វីយ៉ាម ។



**មេរៀនទី ១១**

# ស្វ៍ឡាត្ទ៉ (صلاة)

ស្វ៍ឡាត្ទ៉គឺការគោរពបូជា (នមស្ការ) អល់ឡោះហ្វ៍តាអាឡា រៀងរាល់ថ្ងៃ ដែលមុស្លីមទាំងអស់ប្រតិបត្តិប្រាំដងក្នុងមួយថ្ងៃ ។

នៅក្នុងស្វ៍ឡាត្ទ៉ អ្នកទាំងអស់គ្នានិយាយរកអល់ឡោះហ្វ៍តាអាឡា ដូច្នេះអ្នកទាំងអស់គ្នាចូរប្រតិបត្តិឲ្យអស់ពីសមត្ថភាព ។ យកល្អឲ្យស្លៀកពាក់ស្អាត ឲ្យដុសធ្មេញ ឲ្យសិតសក់ ហាក់ដូចជាអ្នកទាំងអស់គ្នាទៅជួបលោកអ្នកធំណាម្នាក់អញ្ចឹងដែរ ។ អល់ឡោះហ្វ៍តាអាឡាសំខាន់ជាងសត្វលោកទាំងអស់ទៅទៀត ។

មុននឹងបំពេញស្វ៍ឡាត្ទ៉ (នមស្ការ) អ្នកទាំងអស់គ្នាត្រូវធ្វើវូឌុអ៊្ (وضوء) សិន ។ នេះគឺរបៀបលាងសម្អាតមួយពិសេសដែលព្រះសាស្តាﷺបានបង្ហាត់យើង ។

អ្នកទាំងអស់គ្នា អាចនិយាយរកអល់ឡោះហ្វ៍តាអាឡាបានពេលណាក៏បានដែរ ស្រេចតែអ្នកទាំងអស់គ្នា អ្នកទាំងអស់គ្នាមិនបាច់រង់ចាំឲ្យដល់ពេលស្វ៍ឡាត្ហ៍ (នមស្ការ) សិនទេ ។

ស្វ៍ឡាត្ហ៍ជាមធ្យោបាយនិយាយរក អល់ឡោះហ្វ៍តាអាឡាដែលព្រះសាស្ដាﷺបានបង្រៀនយើង ។ នេះជារបៀបពិសេសមួយ ដូច វូឌុអ៍ (وضوء) ដែលជារបៀបលាងសម្អាតពិសេសមួយដែរនោះ ។

ពេលបំពេញស្វ៍ឡាត្ហ៍ (នមស្ការ) យើងត្រូវផ្ដោតអារម្មណ៍ទៅរកអល់ឡោះហ្វ៍តាអាឡាតែមួយគត់ និងយកចិត្តទុកដាក់លើអ្វីដែលយើងកំពុងតែសូត្រក្នុងស្វ៍ឡាត្ហ៍យើងនោះ ។ យើងគប្បីបំពេញស្វ៍ឡាត្ហ៍យឺតៗនិងច្បាស់លាស់ យើងគប្បីធ្វើនមស្ការនៅពេលដែលបានកំណត់ស្រេចហើយ ដ្បិតយើងមិនត្រូវបង្អែបង្អង់ទៅនិយាយរកអល់ឡោះហ្វ៍តាអាឡាទេ ពីព្រោះយើងស្រឡាញ់អល់ឡោះហ្វ៍តាអាឡាណាស់ ។



## កិច្ចការសិស្ស ១១

ចូរគូរពេលធ្វើស្វ៍ឡាត្ហ៍ថ្ងៃរសៀលពិសេស នៅលើនាឡិកាខាងក្រោមនេះ ដែលអ្នកបានធ្វើនៅឯសាលា ។




ចូរផាត់ព័ណ៌លើនាឡិកានេះ ។



តក្បិរ



តក្បិរបាសូ

១) កន្ទេកប្រអប់ជើងបន្តិច
២) លើកដៃដល់ត្រចៀក (មេដៃនៅក្រោយត្រចៀក)
៣) ដាក់ភ្នែក (មើលទៅឯតួរបាសូ)

១) ប្រអប់ជើងជិតគ្នា
២) --------------
៣) --------------





តក្បិរ



តក្បិរបាសូ

១) កន្ទេកប្រអប់ជើងបន្តិច
២) សំយុងដៃតាមដងខ្លួន
៣) ម្រាមដៃរួមគ្នា
៤) ដាក់ភ្នែក (មើលទៅឯទូរបាសូ)
៥) ទម្លាក់ស្មា

១) ប្រអប់ជើងជិតគ្នា
២) ----------
៣) ----------
៤) ----------
៥) ----------

## កិច្ចការសិស្ស ១២

ឲ្យប្រុសៗផាត់ព័ណ៌លើរូបតួលិបកំពុងឈរគ្ចីយ៉ាម ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបតួលីបាស្វកំពុងឈរគ្ចីយ៉ាម ។



ចូរគូសរង្វង់មូលត្រង់ចំណុចទាំង ៥ ដែលបានរៀនរួចហើយ (ប្រអប់ជើង ដៃ ម្រាមដៃ ភ្នែក ស្មា) ។



## មេរៀនទី ១៣

# ស្ម័ឡាត់ - តាក់បីរ៉ទុល អិះហ្រ៉ាម

ដើម្បីចាប់ផ្តើមប្រតិបត្តិស្ម័ឡាត់ អ្នកទាំងអស់គ្នាត្រូវឈរគ្ចីយ៉ាម បន្ទាប់មក សូត្រតាក់បីរ៉ទុល អិះហ្រ៉ាម ។

តាក់បីរ៉ទុល អិះហ្រ៉ាម ជាការសូត្រថា អល់ឡហ្វ អាក់ប៉ារ ទីមួយដែលអ្នកទាំងអស់គ្នាសូត្រនៅក្នុងស្ម័ឡាត់ ។ គេសូត្រតាក់បីរ៉ទុល អិះហ្រ៉ាម នេះក្រោយពីនៀតរួច (គឺក្រោយពីបាននឹកក្នុងចិត្តថាចង់ធ្វើអ្វី និងធ្វើដើម្បីអ្នកណា) ។

ក្នុងពេលសូត្រ តាក់បីរ៉ទុល អិះហ្រ៉ាម នេះ អ្នកទាំងអស់គ្នាត្រូវលើកដៃទាំងពីរឡើង ឲ្យមេដៃនៅក្រោយត្រចៀក ។

ពេលណាអ្នកទាំងអស់គ្នាសូត្រថា អល់ឡហ្វ អាក់ប៉ារ ពេលនោះស្ម័ឡាត់ របស់អ្នកទាំងអស់គ្នាចាប់ផ្តើមហើយ ។

តួលិបនិងប្អូនស្រីគេកំពុងតែសូត្រ តាក់បីរ៉ទុល អិះហ្រ៉ាម៖

## កិច្ចការសិស្ស ១៤

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្ថ៍លិបកំពុងរូគុអ៍ ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបត្ថ៍លីបាស់កំពុងរូគុអ៍ ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៥ ដែលបានរៀនរួចហើយ (ប្រអប់ជើង ដៃ ភ្នែក ជើង ខ្នង) ។



## កិច្ចការសិស្ស ១៣

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្ថ៍លិបកំពុងឈរ គឺយ៉ាមស្វូត្រ តាក់ប៊ីរ៉ទុល អិះហ្រ៍រ៉ម ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបត្ថ៍លីបាស់កំពុងឈរ គឺយ៉ាមស្វូត្រ តាក់ប៊ីរ៉ទុល អិះហ្រ៍រ៉ម ។





ចូរគូសរង្វង់មូលត្រង់ចំណុចទាំង ៣ ដែលបានរៀនរួច ហើយ (ប្រអប់ជើង ដៃ ភ្នែក) ។

## មេរៀនទី ១៤

# ស្ហ៏ទ្បាត់ - រូគុអ៏ (رُكوع)

ក្នុងការបំពេញស្ហ៏ទ្បាត់ បន្ទាប់ពីបានឈរគ្ហីយ៉ាមហើយ អ្នកទាំងអស់គ្នាត្រូវ រូគុអ៏ ។

រូគុអ៏គឺការឱន ចាត់ទុកថាត្រូវបើពាក់កណ្ដាលខ្លួនអ្នកកោង ។

រូគុអ៏ប្រុសនិងរូគុអ៏ស្រីខុសគ្នា ។

ខាងក្រោមនេះ រូបត៏្លិបនិងប្អូនគេកំពុងរូគុអ៏៖







| ត៏្លិប | ត៏្លីបាស្ហ់ |
|---|---|
| ១) កន្ទែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) ដាក់ដៃលើជង្គង់ | ២) -------- |
| ៣) សម្លឹងមើលក្រោម (មើលជើង) | ៣) -------- |
| ៤) សន្ធឹងជើង (ជើងត្រង់) | ៤) មិនសន្ធឹងជើងទេ |
| ៥) ខ្នងរាបស្មើ | ៥) -------- |

**មេរៀនទី ១៦**

# ស្ហ៏ឡាត់ - យ៉ូលុស

ក្នុងចន្លោះពីរស៊ូយ៉ូដ្ង មានយ៉ូលុសមួយ ។

យ៉ូលុសគឺការអង្គុយ ។

នៅលើរូបនេះ ត៏្ហលិបនិងប្អូនស្រីកំពុងអង្គុយយ៉ូលុស ។



ត៏្ហលិប



ត៏្ហលីបាស៊ុ

| | |
|---|---|
| ១) ដាក់ប្រអប់ជើងស្តាំលើប្រអប់ជើងឆ្វេង | ១) ------------- |
| ២) ដាក់ដៃលើភ្លៅ | ២) ------------ |
| ៣) ភ្នែកសម្លឹងមើលទៅឯទូរបាស៊ុ | ៣) ------------- |



**មេរៀនទី ១៥**

# ស្ហ៏ឡាត់ - សាច់ដ្ងាស៊ុ (سجدة)

បន្ទាប់ពីបានរូគុអ៊ុហើយ អ្នកត្រូវឈរគ្ហីយ៉ាម បន្ទាប់មកទើបធ្វើសាច់ដ្ងាស៊ុ ។

សាច់ដ្ងាស៊ុគឺការក្រាបដោយឲ្យថ្ងាសប៉ះផ្ទៃកម្រាល ព្រមទាំងបាតដៃ ជង្គង់ និងមេជើងផង ។

ក្នុងរ៉ក់អ៊ាស៊ុ(ركعة)នីមួយៗមានពីរស៊ូយ៉ូដ្ង កាត់ចែកដោយយ៉ូលុស មួយ ។

សាច់ដ្ងាស៊ុប្រុសនិងសាច់ដ្ងាស៊ុស្រីខុសគ្នា ។

នៅលើរូបនេះ ត៏្ហលិបនិងប្អូនស្រីកំពុងក្រាបសាច់ដ្ងាស៊ុ ។



ត្ត៏លិប



ត្ត៏លីបាស្វ់

| ត្ត៏លិប | ត្ត៏លីបាស្វ់ |
| --- | --- |
| ១) ប្រអប់ជើងឃ្លាតគ្នាបន្តិច (មេជើងប៉ះផ្ទៃកម្រាល) | ១) ប្រអប់ជើងជិតគ្នា (មេជើងប៉ះផ្ទៃកម្រាល) |
| ២) ភ្នែកសម្លឹងទៅចុងច្រមុះ | ២) ------------ |

(ម្រាមដៃជិតគ្នា តម្រង់ទៅរកគ្ឹបឡាស្វ់ ក្បែរត្រចៀក)

| | |
| --- | --- |
| ៣) កែងដៃមិនប៉ះផ្ទៃកម្រាល (ឃ្លាតពីដងខ្លួនបន្តិច) | ៣) កែងដៃប៉ះផ្ទៃកម្រាល (មិនឃ្លាតពីដងខ្លួនទេ) |



## កិច្ចការសិស្ស ១៥

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្ត៏លិបកំពុងក្រាបសាច់ដ្វាស្វ់ ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបត្ត៏លីបាស្វ់កំពុងក្រាបសាច់ដ្វាស្វ់ ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយទាក់ទងនឹងប្រអប់ជើង ម្រាមដៃ ថ្ងាស ភ្នែក កែងដៃ ។

ចូរគូសរង្វង់មូលលើចំណុចទាំង ៧ ដែលត្រូវតែប៉ះផ្ទៃកម្រាលក្នុងពេលក្រាបសាច់ដ្វាស្វ់ ដោយដាក់ព័ណ៌ខុសគ្នា ។

## កិច្ចការសិស្ស ១៧

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្ដ៏លិបកំពុងឈរសូត្រគុនូត ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបត្ដ៏លីបាស្ញ់កំពុងឈរសូត្រគុនូត ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយ
ទាក់ទងនឹងប្រអប់ជើង ប្រអប់ដៃ ភ្នែក ។



## កិច្ចការសិស្ស ១៦

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្ដ៏លិបកំពុងអង្គុយយ៉្ហូលុស ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបត្ដ៏លីបាស្ញ់កំពុងអង្គុយយ៉្ហូលុស ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយ
ទាក់ទងនឹងប្រអប់ជើង ដៃ ភ្នែក ។

**មេរៀនទី ១៧**

# ស្វ៏ឡាត់ - គុ៊នូត

ក្នុងរ៉ក់អាស់ទី ២ នៅពេលកំពុងឈរគីយ៉ាម ពេលស្វ៏ឡាត់ គប្បីសូត្រគុ៊នូតមុននឹងរុកុអ៊ ។

គុ៊នូតគឺការលើកដៃឡើង ដោយលាតប្រអប់ដៃឆ្ពោះទៅឯមេឃ ។

នៅលើរូបនេះ ត៏លិបនិងប្អូនស្រីកំពុងសូត្រគុ៊នូត ។





ត៏លិប



ត៏លីបាស់

| ត៏លិប | ត៏លីបាស់ |
| --- | --- |
| ១) ប្រអប់ជើងឃ្លាតគ្នាបន្តិច | ១) ប្រអប់ជើងជិតគ្នា |

២) ដាក់ដៃចំពីមុខ បាតដៃលាតទៅឯមេឃ ប្រអប់ដៃនិងម្រាមដៃជាប់គ្នា

| | |
| --- | --- |
| ៣) ភ្នែកសម្លឹងមើលប្រអប់ដៃ | ៣) ----------------- |



គ្ងីយ៉ាម គ្ងុនូត រូគុអ៏ គ្ងីយ៉ាម



សាច្ញ់ដ្វាស៊ូ ឃ្ញូលុស



សាច្ញ់ដ្វាស៊ូ ឃ្ញូលុស (ចប់)

កំណែលើកទី ២, 06/2020



**មេរៀនទី ១៨**

# កាយវិការក្នុងស្ម័ទ្បាត់



តាក់បីរ៉ទុល អិះហ្រ៉ាម គ្ងីយ៉ាម រូគុអ៏ គ្ងីយ៉ាម



សាច្ញ់ដ្វាស៊ូ ឃ្ញូលុស សាច្ញ់ដ្វាស៊ូ


ឃ្ជុលុស


គ្វីយ៉ាម


គ្វូនូត


រុគុអ៍


គ្វីយ៉ាម


សាច់ដ្វាស់


ឃ្ជុលុស


សាច់ដ្វាស់


ឃ្ជុលុស (ចប់)




តាក់បីរ៉ទុល អ៊ិះហ្រ៉ាំម


គ្វីយ៉ាម


រុគុអ៍


គ្វីយ៉ាម


សាច់ដ្វាស់


ឃ្ជុលុស


សាច់ដ្វាស់


ឃ្ជុលុស